# តើអេអេសម្រេចយ៉ាងដូចម្ដេច?

យើងកម្រឃើញនរណាម្នាក់ដែលបានដើរតាមគម្រោងផែនការណ៍របស់យើងយ៉ាងម៉ត់ចត់ហើយ ទទួលភាពបរាជ័យនោះឡើយ។ តែចំពោះអ្នកដែលមិនបានស្ដារជីវិតរបស់ពួកគេឲ្យចេញពីភាពអាប់អួរបាននោះគឺព្រោះតែគេមិនបានផ្ដល់ឱកាស ដល់ខ្លួនរបស់គេក្នុងការចូលរួមក្នុងកម្មវិធីនោះឲ្យបានពេញលេញទៅវិញទេ។ ជាទូលទៅបុរស និងស្ត្រីអ្នកដែលគ្មានសមត្ថភាពគ្រប់គ្រាន់ក៏ព្រោះតែពួកគេគឺជាមនុស្សដែលគ្មានភាពស្មោះត្រង់លើខ្លួនឯង។ប៉ុន្តែ ផ្ទុយមកវិញ ពួកគេមិនមានកំហុសទេពីព្រោះពួកគេបានកើតមកដោយជីវិតរស់នៅបែបនោះគេមិនមាន សមត្ថភាពយល់ និងគ្មានសមត្ថភាពអាចកសាងជីវិតរបស់គេដើម្បីអភិវឌ្ឍន៍ជីវិតរស់នៅរបស់គេដោយភាពស្មោះត្រង់បាន។ ប៉ុន្តែពួកគេមានឱកាសក្នុងការកែប្រែតិចជាងពាក់កណ្ដាលប៉ុណ្ណោះ។ ផងដែលនោះក៏មានអ្នកដែលបានទទួលរងផ្នែកផ្លូវអារម្មណ៍ និងផ្លូវចិត្តដ៏ធ្ងន់ធ្ងរទៀតផង ប៉ុន្តែភាគច្រើននៃពួកគេអាចស្រោចស្រង់មកវិញបានប្រសិនបើគេមានសមត្ថភាពដើម្បីឲ្យមានភាពស្មោះត្រង់។

យើងបានបង្ហាញពីប្រវត្តិផ្ទាល់ខ្លួនរបស់ពួកយើងចំពោះអ្វីដែលយើងធ្លាប់ឆ្លងកាត់តើវាបានកើត ឡើងយ៉ាងដូចម្ដេច? ហើយឥឡូវយើងបានធ្វើអ្វីខ្លះទៅហើយចំពោះវា? ប្រសិនបើអ្នកបាន មើលឃើញជីវិតរបស់ពួកយើងដែលប្រែចិត្តហើយ ដែលមានជីវិតល្អប្រសើរហើយ តើអ្នកមានបំណងចង់ឲ្យជីវិតរបស់អ្នកបានទទួលភាពជោគជ័យដូចយើងដែលឬទេ? ហើយតើអ្នកមានការប្ដេជ្ញាចិត្ត ហើយនិងព្រមធ្វើអ្វីគ្រប់យ៉ាងដើម្បីឈោងចាប់យកភាពជោគ ជ័យនោះមែនដែរឬទេ? ប្រសិនបើអ្នកពិតជាចង់បានភាពជោគជ័យនោះ នោះអ្នកនឹងត្រៀម ខ្លួន រួច ជាស្រេចក្នុងចាប់យកជំហានទាំងនោះហើយ។

យើងមានដំបូន្មានខ្លះៗសម្រាប់អ្នក ប្រសិនបើអ្នកចង់ស្វែងយល់ពីអេអេឲ្យបានច្បាស់ សូមបងប្អូនព្យាយាមយកចិត្តទុកដាក់ឲ្យខ្លាំងជាងមុនបន្ថែមទៀត ចាប់តាំងតែពីដំបូងតទៅ។ សម្រាប់បញ្ហាខ្លះយើងមានភាពរុញរា យើងគិតថាយើងគួរតែអាចមានដំណោះស្រាយដ៏ងាយ ប៉ុន្តែយើងបែរជាមិនមានទៅវិញ។នេះគឺជាដំបូន្មានរបស់យើង ដែលយើងធ្លាប់ឆ្លងកាត់ហើយ យើងសូមឲ្យអ្នកកុំឲ្យមានភាពភ័យខ្លាច និងម៉ត់ចត់ចំពោះរាល់ការចាប់ផ្ដើមទាំងអស់។ អ្នកខ្លះបានព្យាយាមប្រកាន់ខ្ជាប់នូវគំនិតចាស់ៗរបស់ពួកគេពីមុនដែលវាគ្មានលទ្ធផលអ្វីសោះ

ដូននេះបើយើងចង់ទទួលបានលទ្ធផលល្អលុះត្រាតែយើងបោះវាចោល។ សូមបោះបង់គំនិតខុសឆ្គងរបស់ខ្លួនអ្នកចោលហើយឈោងចាប់យកអ្វីដែលថ្មីពីអេអេ។

កុំភ្លេចថាពួកយើងកំពុងតែប្រឈមមុខជាមួយនឹងស្រា ស្រាវាមានភាពវាងវៃ ហើយមានកលល្បិច វាមានអំណាច ហើយយើងពិតជាពិបាកយល់ពីវាបានច្បាស់បានឡើយ ប្រសិនបើគ្មានការជួយពីនរណាទេនោះវាគឺពិតជាលំបាកណាស់សំរាប់យើង ប៉ុន្តែមានម្នាក់ដែលមានគ្រប់អំណាចទាំងអស់នោះគឺព្រះជាម្ចាស់ សូមពួកយើងស្វែងរកទ្រង់ឥឡូវនេះ។ បើយើងមិនបានតាំងចិត្តឲ្យបានពេញលេញនោះទេ នោះយើងនិងមិនបានទទួលប្រយោជន៍អ្វីទាំងអស់។ យើងកំពុងឈរនៅចំណុចមួយដែលត្រូវតែពិចារណាថាតើយើងគួរតែជ្រើសរើសផ្លូវមួយណា? យើងបានសុំឲ្យទ្រង់ជួយការពារ និងថែរក្សាពួកយើងទាំងស្រុងលើគ្រប់ចំណុច។

ទាំងនេះគឺជាជំហានដែលយើងស្នើរឲ្យប្រើសម្រាប់កម្មវិធីដើម្បីផ្តាច់ការញៀនស្រា និងស្តារជីវិតយើងឡើងវិញ

1. យើងសារភាពថាយើងគ្មានអំណាចលើស្រាទេ ហើយយើងពិតជាមិនអាចគ្រប់គ្រងជីវិតរបស់យើងបានទេ។
2. ចូរមកជឿលើអំណាចមួយដែលជាអំណាចដ៏អស្ចារ្យជាងខ្លួនយើង ហើយជាអំណាចមួយដែលអាចជួយស្តារជីវិតរបស់យើងឲ្យមានភាពល្អប្រក្រតីឡើងវិញ។
3. គួរសម្រេចចិត្តផ្តល់ជូនចំពោះព្រះណាមួយដែលអ្នកជឿជាក់ និងទុកចិត្ត ហើយផ្តល់ទៅទ្រង់រាល់នូវសិទ្ធិអំណាចរបស់ខ្លួនយើងទាំងគោលបំណង និងជីវិតរបស់ពួកយើង ដើម្បីឲ្យទ្រង់រៀបចំចាត់ចែងតាមហឫទ័យទ្រង់។
4. សូមកុំមានភាពភ័យខ្លាច និងត្រូវវាយតំលៃលើខ្លួនឯងឲ្យបានច្បាស់លាស់។
5. ចូរសារភាពនូវកំហុសទាំងនោះចំពោះព្រះជាម្ចាស់ សារភាពចំពោះខ្លួនឯង និងចំពោះមនុស្សផ្សេងទៀតអំពីកំហុសរបស់ពួកយើងដែលបានធ្វើ។
6. ជូនចុះយើងបានត្រៀមខ្លួនរួចជាស្រេចហើយដើម្បីឲ្យទ្រង់ដកចេញនូវចរិកលក្ខណះអាក្រក់ទាំងឡាយនោះ។
7. ចូរទូលសូមទៅទ្រង់ដោយបន្ទាបខ្លួន ដើម្បីឲ្យទ្រង់ដកចេញនូវចរិកលក្ខណះអាក្រក់របស់យើងទាំងនោះ។
8. ចូរធ្វើការស្រង់នូវចំនួននៃមនុស្សអ្នកដែលអ្នកធ្លាប់ធ្វើអ្វីមិនល្អ ហើយមានកំហុសចំពោះអ្នកទាំងកន្លងមកនោះ បន្ទាប់មកព្រមទទួលនូវកំហុសទាំងនោះ ហើយចូលធ្វើការលុបលាងកំហុសទាំងនោះចំពោះពួកគេវិញ។
9. ចូរធ្វើការលុបលាងកំហុសទាំងនោះដោយផ្ទាល់ចំពោះអ្នកទាំងនោះ នៅកន្លែងណាមួយ ឬពេលណាមួយក៏បានបើអាចធ្វើបាន លើកលែងតែកន្លែងណា ឬពេលណាដែលនិងអាចធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្ត និងប្រយោជន៍របស់គេ។

10. នៅតែបន្តក្នុងការត្រួតពិនិត្យលើរាល់ទង្វើរបស់ខ្លួនយើង ហើយនៅពេលណាដែលយើងធ្វើវាខុស សូមឲ្យយើងសារភាពនូវកំហុសនោះភ្លាម។
11. ចូរបានធ្វើការស្វែងរកតាមរយៈការអធិដ្ឋាន ហើយធ្វើការសញ្ជឹងគិតដើម្បីពង្រឹងស្មារតីរបស់យើងក្នុងការទំនាក់ទំនងជាមួយព្រះអង្គម្ចាស់ដូចដែលយើងបានយល់អំពីទ្រង់។ យើងនៅតែមានការអធិដ្ឋានដើម្បីយល់អំពីហទ័យរបស់ព្រះអង្គ និងអំណាចដើម្បីឲ្យសម្រេចវាទៅ។
12. មានការភ្ញាក់ឡើងវិញនូវព្រលឹងវិញ្ញាណដែលវាជាលទ្ធផលនៃជំហានទាំងនេះ។ យើងកំពុងតែយកសារនេះទៅចែកចាយដល់អ្នកដែលញៀនស្រា។ ហើយយកទៅអនុវត្តនូវគោលការណ៍ទាំងនេះនៅក្នុងជំហានទាំង១២របស់យើង។

គ្មាន អ្នកណាម្នាក់អាចធ្វើតាមគោលការណ៍របស់អេអេបានល្អឥតខ្ចោះទេ ព្រោះពួកយើងភាគច្រើនបានស្រែកថា “វាពិតជាលំបាកណាស់ ពួកយើងមិនព្រមទទួលយកវាទេ” ត្រូវចាំថាយើងមិនមែនជាមនុស្សបរិសុទ្ធទេ តែយើងជាមនុស្សដែលសុកចិត្តរីកលូតលាស់តាមឥទ្ធិពលនៃព្រលឹងវិញ្ញាណ។ គោលការណ៍របស់អេអេជាមធ្យោបាយណែនាំមួយដែលជួយឲ្យយើងអាចអភិវឌ្ឍន៍ជីវិតបានល្អប្រសើរ។ អេអេជួយលើកទឹកចិត្តយើងឲ្យទទួលបានជោគជ័យតាមដំណើរការខាងព្រលឹងវិញ្ញាណ មិនមែនជួយយើងអោយក្លាយទៅជាមនុស្សគ្រប់លក្ខនោះទេ។ ការបកស្រាយរបស់ពួកយើងស្តីអំពីអ្នកញៀនស្រា ហើយនឹងមេរៀននិយាយអំពីអ្នកមិនជឿពិតប្រាកដ និងព្រមទាំងនិយាយអំពីដំណើរជីវិតមុន និងក្រោយពីចូលអេអេ មានបីចំណុចដែលអាចជួយយើងឲ្យបានយល់កាន់តែច្បាស់ពីអេអេ

a) ពួកយើងគឺពិតជាអ្នកដែលញៀនស្រា ហើយមិនអាចគ្រប់គ្រង់លើជីវិតខ្លួនឯងបានមែន
b) វាប្រហែលពិតជាគ្មានអំណាចនៃមនុស្សណាម្នាក់អាចជួយស្រោចស្រង់យើងឲ្យផុតពីការញៀននោះបានទេ
c) ព្រះអាចនឹងធ្វើបើសិនជាយើងបានស្វែងរកព្រះអង្គ។